ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 37

# សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ

## Provisions, Contingent Liabilities and Contingent Assets

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**



បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឲ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង“ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឲ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ **ស្តង់ដារគណនេយ្យកម្ពុជា** ដែលរួមមាន“ ***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា*** ” និង “***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម***” ត្រូវបានដាក់ឲ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឲ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឌី តាយី**

## គោលបំណង

កម្មវត្ថុនៃស្តង់ដានេះ គឺដើម្បីធានាថា លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ និង មូលដ្ឋាន នៃការវាស់វែងសមស្របត្រូវបានអនុវត្តចំពោះសំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ ហើយថា ព័ត៌មានគ្រប់គ្រាន់ត្រូវបានលាតត្រដាងបង្ហាញនៅក្នុងការកំណត់សម្គាល់ ដើម្បីធ្វើឱ្យអ្នកប្រើប្រាស់អាចយល់ដឹងពីលក្ខណៈពេលវេលា និងចំនួនទឹកប្រាក់របស់ពួកគេ ។

## វិសាលភាព

១ ស្តង់ដានេះ ត្រូវបានអនុវត្ត ដោយសហគ្រាសទាំងអស់ នៅក្នុងគណនេយ្យកម្មសម្រាប់សំវិធានធនបំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ លើកលែងតែៈ

(ក) សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុទាំងនោះ កើតចេញពីកិច្ចសន្យាដែលអាចអនុវត្តន៍បានលើកលែងតែកិច្ចសន្យានាំឱ្យមានការខាតបង់ និង

(ខ) [លុបចោល]

(គ) សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុទាំងនោះ ដែលបានចែងក្នុងស្តង់ដារដទៃទៀតរួចហើយ ។

២ ស្តង់ដានេះ មិនអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុ (រួមទាំងការធានា) ស្ថិតនៅក្នុងវិសាលភាពរបស់ ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* ។

៣ កិច្ចសន្យាប្រតិបត្តិ គឺជាកិច្ចសន្យា ដែលគ្មានភាគីណាមួយមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ឬក៏ភាគីទាំងពីរ មិនបានអនុវត្តនូវផ្នែកខ្លះនៃកាតព្វកិច្ចរបស់ខ្លួនដោយកម្រិតស្មើគ្នា។ ស្តង់ដានេះមិនបានអនុវត្តចំពោះកិច្ចសន្យាដែលនឹងត្រូវអនុវត្តឡើយ លើកលែងតែកិច្ចសន្យានោះនាំឱ្យមានការខាតបង់។

៤ [លុបចោល]

៥ នៅពេលដែលស្តង់ដាផ្សេងទៀតដែលចែងពីប្រភេទជាក់លាក់នៃសំវិធានធន បំណុលយថាហេតុ ឬទ្រព្យសកម្មយថាហេតុ សហគ្រាសត្រូវអនុវត្តតាមស្តង់ដានោះជំនួសឱ្យស្តង់ដានេះ។ឧទាហរណ៍ៈ ប្រភេទសំវិធានធនខ្លះត្រូវបានបង្ហាញនៅក្នុងស្តង់ដាស្តីពីៈ

(ក) កិច្ចសន្យាសាងសង់ (ស.គ.អ.ក ១១ *កិច្ចសន្យាសាងសង់*)

(ខ) ពន្ធលើចំណូល (ស.គ.អ.ក. ១២ *ពន្ធលើប្រាក់ចំណូល*)

(គ) ភតិសន្យា (ស.គ.អ.ក ១៧ *ភតិសន្យា*)។ ទោះបីជាយ៉ាងណាក៏ដោយ ស.គ.អ.ក ១៧ នេះ មិនមានសេចក្តីតម្រូវ ដើម្បីដោះស្រាយចំពោះភតិសន្យាប្រតិបត្តិការដែលក្លាយ ទៅជាការខាតបង់ (ស្តង់ដានេះ អនុវត្តចំពោះក្នុងករណីរបៀបនេះ) និង

(ឃ) អត្ថប្រយោជន៍និយោជិក (សូមមើល ស.គ.អ.ក ១៩ *អត្ថប្រយោជន៍និយោជិក*) និង

(ង) កិច្ចសន្យាធានារ៉ាប់រង (ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង*)។ ទោះបីជាយ៉ាងណាក៏ ដោយស្តង់ដានេះប្រើប្រាស់ ចំពោះសំវិធានធន បំណុលជាយថាហេតុ និងទ្រព្យសកម្មជាយថាហេតុរបស់ក្រុមហ៊ុនធានារ៉ាប់រង លើកលែងតែ រឿងទាំងនេះវាកើតចេញពីបំណុល និងទ្រព្យ ដែលកើតចេញពីកិច្ចសន្យា ដែលស្ថិតនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៤ ។

៦- ចំនួនទឹកប្រាក់ខ្លះដែលត្រូវបានចាត់ទុកជាសំវិធានធន អាចទាក់ទិននឹងការទទួលស្គាល់ផលរបរ ឧទាហរណ៍÷ នៅពេលដែលសហគ្រាសផ្តល់នូវការធានា ដើម្បីជាថ្នូរនឹងប្រាក់ឈ្នួល។ ស្តង់ដានេះមិនបង្ហាញពីការទទួលស្គាល់នៃផលរបរឡើយ។ ស.គ.អ.ក ១៨ *ផលរបរ* កំណត់នូវកាលៈទេសៈដែលផលរបរត្រូវបានគេទទួលស្គាល់ ហើយផ្តល់នូវការណែនាំអនុវត្តជាក់ស្តែងពីលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់។ ស្តង់ដានេះ ក៏មិនបានប្តូរនូវសេចក្តីតម្រូវនានា នៃស្តង់ដា ស.គ.អ.ក ១៨ទេ ។

៧- ស្តង់ដានេះផ្តល់និយមន័យពីសំវិធានធនថា ជាបំណុលដែលមានពេលវេលា និងទឹកប្រាក់មិនច្បាស់លាស់។ នៅក្នុងប្រទេសមួយចំនួន ពាក្យស័ព្ទ "សំវិធានធន" ត្រូវបានគេប្រើផងដែរនៅក្នុងបរិបទ នៃធាតុជាច្រើន ដូចជារំលស់ការធ្លាក់ចុះនៃតំលៃទ្រព្យសកម្ម និងបំណុលជាប់សង្ស័យ។ ទាំងអស់នេះ គឺជាការកែសម្រួល ទៅលើតំលៃយោងនៃទ្រព្យសកម្ម ហើយមិនបានលើកយកមកបង្ហាញក្នុងស្តង់ដានេះទេ ។

៨ ស.គ.អ.ក ដទៃទៀត បានបញ្ជាក់ច្បាស់លាស់ថា តើចំណាយណាខ្លះចាត់ទុកថា ជាទ្រព្យសកម្ម ឬជាចំណាយ។ បញ្ហាទាំងនេះមិនត្រូវបានបរិយាយនៅក្នុងស្តង់ដានេះទេ។ ដូច្នេះហើយស្តង់ដានេះមិនហាមឃាត់ ឬពុំបានតម្រូវឱ្យធ្វើមូលធនកម្ម នៃថ្លៃដើមដែលបានទទួលស្គាល់នៅពេលសំវិធានធន មួយត្រូវបានបង្កើតឡើងឡើយ ។

៩ ស្តង់ដានេះ អនុវត្តចំពោះសំវិធានធនសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ (រួមបញ្ចូលទាំងកិច្ចប្រតិបត្តិការមិនបន្តផង)។ ពេលដែលការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីឆ្លើយតបទៅនឹងនិយមន័យនៃកិច្ចប្រតិបត្តិការមិនបន្ត នោះការលាតត្រដាងបង្ហាញបន្ថែមទៀត អាចត្រូវបានតម្រូវដោយ ស.រ.ហ.អ.ក ៥ *ទ្រព្យសកម្មរយៈពេលវែងទុកសម្រាប់លក់និងកិច្ចប្រតិបត្តិការមិនបន្ត*។

## និយមន័យ

១០ ពាក្យស័ព្ទខាងក្រោមនេះត្រូវបានប្រើនៅក្នុងស្តង់ដានេះហើយ ដែលមានអត្ថន័យបញ្ជាក់ដូចតទៅ

*សំវិធានធន* **គឺជាបំណុលដែលមានទឹកប្រាក់និងពេលវេលាមិនច្បាស់លាស់**

*បំណុល* **គឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់សហគ្រាស ដែលកើតឡើងដោយសារព្រឹត្តិការណ៍អតីតកាល ការទូទាត់នៃបំណុល ត្រូវបានរំពឹងថានាំឱ្យមានលំហូរចេញ នៃធនធានពីសហគ្រាសដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ច ។**

*ព្រឹត្តិការណ៍កាតព្វកិច្ច* គឺជាព្រឹត្តិការណ៍មួយដែលបង្កើតបាននូវកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលកើតឡើងក្នុង សហគ្រាសមួយដែលមិនទាន់ដឹងប្រាកដប្រជា ដើម្បីទូទាត់នូវបំណុលនោះ។

*កាតព្វកិច្ចផ្លូវច្បាប់* គឺជាបំណុលដែលបានមកពី ÷

(ក) កិច្ចសន្យា (តាមរយៈលក្ខខណ្ឌច្បាស់លាស់ ឬ បង្កប់នៃកិច្ចសន្យា)

(ខ) ច្បាប់

(គ) កិច្ចប្រតិបត្តិនៃច្បាប់ផ្សេងទៀត

*កាតព្វកិច្ចប្រយោល* គឺជាកាតព្វកិច្ចមួយដែលកើតចេញពីសកម្មភាពរបស់សហគ្រាសៈ

(ក) ដោយគំរូនៃការអនុវត្តនាអតីតកាល ដែលបានបង្កើតឡើងដោយគោលនយោបាយ ដែលបានបោះផ្សាយ ឬរបាយការណ៍ថ្មីជាក់លាក់ ដែលសហគ្រាសបានបង្ហាញទៅភាគីដទៃទៀតថានឹងព្រមទទួលយកនូវការទទួលខុសត្រូវជាក់លាក់មួយចំនួន និង

(ខ) ជាលទ្ធផល ដែលសហគ្រាសបានបង្កើតនូវការរំពឹងទុក ដែលមានសុពលភាព ទៅលើផ្នែកនៃបំណុលទាំងនោះ នៅពេលដែលភាគីដទៃទៀត នឹងរ៉ាប់រងលើការទទួលខុសត្រូវនោះ។

*បំណុលយថាហេតុ* គឺជាៈ

(ក) បំណុលដែលអាចកើតមាន ដែលកើតចេញពីព្រឹត្តិការណ៍អតីតកាល ហើយវត្តមានរបស់វា ត្រូវបានបញ្ជាក់ច្បាស់ថាអាចកើតឡើង ឬមិនអាចកើតមានឡើងនៃព្រឹត្តិការណ៍នាពេល

អនាគតដែលមិនប្រាកដប្រជាមួយ ឬច្រើនដែលវាមិនស្ថិតនៅក្រោមការគ្រប់គ្រង របស់សហគ្រាសទាំងស្រុងឡើយ ។

(ខ) កាតព្វកិច្ចបច្ចុប្បន្ន ដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល ប៉ុន្តែមិនត្រូវបានគេទទួលស្គាល់ ពីព្រោះតែ:

(១) មិនទំនងជាថា ការហូរចេញនៃធនធាន ដែលមានផលប្រយោជន៍សេដ្ឋកិច្ចត្រូវបានគេតម្រូវឱ្យមានដើម្បីទូទាត់នូវកាតព្វកិច្ចនោះ ឬ

(២) ទឹកប្រាក់នៃកាតព្វកិច្ច មិនអាចវាស់វែងដោយភាពជឿជាក់បាន។

*ទ្រព្យសកម្មយថាហេតុ* គឺជាទ្រព្យសកម្មដែលអាចកើតមាន ដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល ហើយវត្តមានរបស់វាត្រូវបានបញ្ជាក់ច្បាស់ថាអាចកើតឡើងឬមិនអាចកើតនៃព្រឹត្តិការណ៍ នាពេលអនាគត ដែលមិនប្រាកដប្រជាមួយ ឬច្រើនហើយដែលវាមិន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគ្រាសទាំងស្រុងឡើយ ។

*កិច្ចសន្យាខាតបង់* គឺជាកិច្ចសន្យាដែលថ្លៃដើមនៃការបំពេញកាតព្វកិច្ចមិនអាចជៀសវាងបាន ដែលលើសពីផលប្រយោជន៍សេដ្ឋកិច្ច ដែលគេរំពឹងថានឹងទទួលបានពីកិច្ចសន្យានោះ ។

*ការរៀបចំរចនាសម្ព័ន្ធ* គឺជាកម្មវិធីមួយដែលត្រូវបានគ្រោង និងត្រូវបានគ្រប់គ្រងដោយគណៈគ្រប់គ្រង ហើយនឹងមានការផ្លាស់ប្តូរជាសារវ័ន្តទាំង:

(ក) វិសាលភាពនៃអាជីវកម្មដែលត្រូវបានអនុវត្តដោយសហគ្រាស ឬ

## (ខ) កិរិយាបទដែលក្រុមហ៊ុនអាជីវកម្មកំពុងអនុវត្ត

### សំវិធានធន និង បំណុលផ្សេងទៀត

១១ សំវិធានធនអាចញែកដាច់ពីបំណុលដទៃទៀត ដូចជា គណនីពាណិជ្ជកម្មត្រូវសង និងគណនីបង្គរ ពីព្រោះវាមានភាពមិនប្រាកដប្រជា អំពីពេលវេលាឬចំនួនទឹកប្រាក់នៃការចំណាយដែលបានតម្រូវឱ្យមាន នាពេលអនាគត ក្នុងការទូទាត់។ ផ្ទុយទៅវិញៈ

(ក) គណនីពាណិជ្ជកម្មត្រូវសងគឺជាបំណុលដែលត្រូវសងសម្រាប់ទំនិញ ឬសេវាដែលត្រូវបានទទួល ឬត្រូវបានផ្គត់ផ្គង់ ហើយត្រូវបានចេញវិក័យបត្រទារប្រាក់ ឬបានយល់ព្រមគ្នាជាផ្លូវការជា មួយអ្នកផ្គត់ផ្គង់ និង

(ខ) គណនីបង្គរ គឺជាបំណុលដែលត្រូវសងថ្លៃទំនិញ ឬសេវា ដែលត្រូវបានទទួល ឬត្រូវបានផ្គត់ ផ្គង់រួចហើយ ប៉ុន្តែមិនទាន់បានបង់ប្រាក់ មិនទាន់ចេញវិក័យបត្រទារប្រាក់ ឬមិនទាន់បាន ព្រមព្រៀងជាផ្លូវការជាមួយអ្នកផ្គត់ផ្គង់ រួមទាំងទឹកប្រាក់ដែលត្រូវសងនិយោជិក (ឧទាហរណ៍ ទឹកប្រាក់ដែលទាក់ទិននឹងប្រាក់វិសមកាលបង្គរទុក)។ ទោះបីជាពេលខ្លះវាមានភាពចាំបាច់ ដើម្បីប៉ាន់ស្មានពីទឹកប្រាក់ ឬពេលវេលា នៃគណនីបង្គរក៏ដោយ ក៏ភាពមិនប្រាកដប្រជាគឺជាទូទៅមានតិចជាងច្រើនសំវិធានធន។ គណនីបង្គរជារឿយៗ ត្រូវបានរាយការណ៍ ជាផ្នែកមួយនៃគណនីពាណិជ្ជកម្មត្រូវសង និង

គណនីបំណុលផ្សេងទៀតត្រូវសងផ្ទុយពីសំវិធានធន ដែលត្រូវបានរាយការណ៍ដាច់ដោយឡែក ។

**ទំនាក់ទំនងរវាងសំវិធានធន និង បំណុលយថាហេតុ**

១២ ក្នុងការគិតទូទៅ សំវិធានធនទាំងអស់ គឺមានលក្ខណៈយថាហេតុ ពីព្រោះវាមានពេលវេលា និងចំនួនទឹកប្រាក់មិនប្រាកដប្រជា។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងស្តង់ដានេះ ពាក្យស័ព្ទ "យថាហេតុ" ត្រូវបានប្រើសម្រាប់បំណុល និងទ្រព្យសកម្មដែលមិនត្រូវបានទទួលស្គាល់ ពីព្រោះ វត្តមានរបស់វា ត្រូវបានគេបញ្ជាក់តែមួយគត់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតដែលមិនប្រាកដប្រជាមួយ ឬច្រើនមិនស្ថិតនៅក្នុងការគ្រប់គ្រងរបស់សហគ្រាសទាំងស្រុងឡើយ។ លើសពីនេះទៀត ពាក្យស័ព្ទ "បំណុលយថាហេតុ" ត្រូវបានប្រើប្រាស់ សម្រាប់បំណុល ដែលមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ ។

១៣ ស្តង់ដានេះញែកដាច់ពីគ្នារវាង:

(ក) សំវិធានធន ដែលត្រូវបានទទួលស្គាល់ថាជាបំណុល (ដោយសន្មតថាការប៉ាន់ស្មាន ដែលគួរឱ្យជឿជាក់មួយអាចនឹងត្រូវគេធ្វើឡើង) ពីព្រោះវាជាបំណុលបច្ចុប្បន្ន ហើយវាទំនងជាមានលំហូរចេញនៃធនធានដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ចត្រូវបានគេតម្រូវ ឱ្យធ្វើការទូទាត់នូវបំណុលនោះ និង

(ខ) បំណុលថាហេតុដែលមិនត្រូវបានទទួលស្គាល់ជាបំណុល ពីព្រោះវាជា

(១) កាតព្វកិច្ចដែលនឹងអាចកើតមាន ហើយមិនទាន់ត្រូវបានគេបញ្ជាក់ថា តើសហគ្រាសមាន បំណុលនាពេលបច្ចុប្បន្នដែលអាចនាំទៅដល់មានលំហូរចេញនៃធនធានដែលតំណាងឱ្យ ផលប្រយោជន៍សេដ្ឋកិច្ចឬទេ? ឬ

(២) កាតព្វកិច្ចពេលបច្ចុប្បន្ន ដែលមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យ ក្នុងការទទួលស្គាល់នៅ ក្នុងស្តង់ដានេះ (ពីព្រោះ វាមិនទំនងជាថា មានតម្រូវការនៃលំហូរចេញនៃធនធាន ដែល តំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ចដើម្បីទូទាត់នូវបំណុលនោះ ឬ មិនអាចបំពេញបាននូវការប៉ាន់ស្មាន ដែលគួរឱ្យជឿជាក់បាននៃចំនួនទឹកប្រាក់បំណុល)។

## ការទទួលស្គាល់

### សំវិធានធន

**១៤** **សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលៈ**

**(ក) សហគ្រាសមួយមានបំណុលនាពេលបច្ចុប្បន្ន(តាមផ្លូវច្បាប់ ឬប្រយោល) ដែលជាលទ្ធផល នៃព្រឹត្តិការណ៍ពីអតីតកាល ។**

**(ខ) វាទំនងថា មានលំហូរចេញនៃធនធានដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ចដែលតម្រូវឱ្យ ទូទាត់នូវបំណុលនោះ ។**

**(គ) ការប៉ាន់ស្មានដែលគួរឱ្យជឿជាក់បាន ទៅលើចំនួនទឹកប្រាក់នៃបំណុលនោះ។**

ប្រសិនបើលក្ខខណ្ឌទាំងអស់នេះ មិនទាន់បានបំពេញទេ គ្មានសំវិធានធនណាដែលត្រូវបានទទួលស្គាល់ឡើយ។

**កាតព្វកិច្ចបច្ចុប្បន្ន**

១៥ មានករណីតិចណាស់ ដែលវាមិនមានភាពច្បាស់លាស់ថាតើមានកាតព្វកិច្ចបច្ចុប្បន្ន ឬក៏គ្មាននោះ។ នៅក្នុងករណីទាំងនេះ មានតែព្រឹត្តិការណ៍អតីតកាលទេ ដែលត្រូវបានចាត់ទុកថាធ្វើឱ្យកើតមាននូវកាតព្វកិច្ចបច្ចុប្បន្ន ប្រសិនបើ ដោយធ្វើការពិចារណាលើភស្តុតាងទាំងអស់ដែលមាន វាទំនងជាកើតមានមែនដែលកាតព្វកិច្ចបច្ចុប្បន្នកើតមានឡើងចុងការិយបរិច្ឆេទរាយការណ៍ ។

១៦ នៅស្ទើរតែគ្រប់ករណីទាំងអស់ វានឹងមានភាពច្បាស់លាស់ថាតើ ព្រឹត្តិ-ការណ៍អតីតកាលមួយ បានធ្វើឱ្យកើតមានកាតព្វកិច្ចបច្ចុប្បន្នដែរ ឬទេ។ នៅក្នុងករណីតិចណាស់ ជាឧទាហរណ៍ ករណីបណ្តឹងមួយ វាអាចបណ្តាលឱ្យមានជំលោះថា តើព្រឹត្តិការណ៍ជាក់លាក់ខ្លះបានកើតឡើងដែរ ឬទេ ហើយថាតើព្រឹត្តិការណ៍ទាំងនោះនាំមក នូវកាតព្វកិច្ចបច្ចុប្បន្នដែរឬទេ ។ នៅក្នុងករណីនោះ សហគ្រាសមួយធ្វើការកំណត់ថាតើ មានកាតព្វកិច្ចបច្ចុប្បន្ន ចុងការិយបរិច្ឆេទរាយការណ៍ដែរ ឬទេ ដោយពិចារណាទៅលើភស្តុតាងទាំងអស់ដែលមានរួមបញ្ចូលនូវឧទាហរណ៍ យោបល់របស់ជំនាញការផង។ ភស្តុតាងដែលត្រូវបានគិតពិចារណា រួមបញ្ចូលនូវភស្តុតាងបន្ថែមណាដែលផ្តល់ ដោយព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ផង ។ ផ្អែកលើមូលដ្ឋាននៃភស្តុតាង ទាំងនោះមាន៖

(ក) នៅពេលដែលវាទំនងថា មានកាតព្វកិច្ចបច្ចុប្បន្នកើតឡើង នៅចុងការិយបរិច្ឆេទរាយការណ៍ សហគ្រាសត្រូវទទួលស្គាល់នូវសំវិធានធន (ប្រសិនលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ ត្រូវបាន បំពេញ) និង

(ខ) នៅពេលដែលវាទំនងថា គ្មានកាតព្វកិច្ចបច្ចុប្បន្ន កើតមាននៅចុងការិយបរិច្ឆេទរាយការណ៍នោះទេ សហគ្រាស ត្រូវលាតត្រដាងបង្ហាញនូវបំណុលយថាហេតុ លើកលែងតែភវនីយភាពនៃលំហូរចេញនៃធនធាន ដែលតំណាងឱ្យ ផលប្រយោជន៍សេដ្ឋកិច្ចមានលក្ខណៈដាច់ស្រយាល (សូមមើលកថាខ័ណ្ឌ ៨៦)។

## ព្រឹត្តិការណ៍អតីតកាល

១៧ ព្រឹត្តិការណ៍អតីតកាលមួយ ដែលបង្កើតឱ្យមានកាតព្វកិច្ចបច្ចុប្បន្ន ត្រូវបានហៅថាព្រឹត្តិការណ៍មានកាតព្វកិច្ច។ សម្រាប់ព្រឹត្តិការណ៍ណាមួយដែលជាព្រឹត្តិការណ៍មានកាតព្វកិច្ច វាចាំបាច់ដែល សហគ្រាសពុំមានជំរើសជាក់លាក់ផ្សេងទៀត ចំពោះការសងទូទាត់កាតព្វកិច្ច ដែលបានបង្កើតដោយព្រឹត្តិការណ៍នោះ ។ ព្រឹត្តការណ៍បែបនោះ កើតឡើងតែក្នុងករណីដែលៈ

(ក) នៅពេលដែល ការទូទាត់កាតព្វកិច្ចនោះ អាចត្រូវបង្ខំឱ្យអនុវត្តដោយច្បាប់។

(ខ) ក្នុងករណីនៃកាតព្វកិច្ចប្រយោល ដែលព្រឹត្តិការណ៍នោះ (ដែលអាចជាសកម្មភាពរបស់សហគ្រាស)បានធ្វើឱ្យភាគីដទៃទៀតរំពឹងថា សហគ្រាសនឹងបំពេញនូវកាតព្វកិច្ចនោះ ។

១៨- របាយការណ៍ហិរញ្ញវត្ថុជាប់ពាក់ព័ន្ធនឹងស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស នៅចុង ការិយបរិច្ឆេទរាយការណ៍ ហើយដែលមិនបង្ហាញពី ស្ថានភាពហិរញ្ញវត្ថុ ដែលអាចកើតឡើងនាពេលអនាគតនោះឡើយ។ ដូច្នេះ មិនមានសំវិធានធនណា ដែលត្រូវបានទទួលស្គាល់ចំពោះចំណាយ ដែលចាំបាច់ត្រូវកើតឡើង សម្រាប់កិច្ចប្រតិបត្តិការ ក្នុងពេលអនាគតឡើយ ។ មានតែបំណុលដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស ជាបំណុលកើតឡើង នៅចុងការិយបរិច្ឆេទរាយការណ៍ ។

១៩ វាជាកាតព្វកិច្ចដែលកើតចេញពី ព្រឹត្តិការណ៍អតីតកាល ដែលកើតឡើងដោយឯករាជ្យនៃសកម្មភាពនាពេលអនាគតរបស់សហគ្រាស (ពោលគឺដំណើរការអាជីវកម្ម នាពេលអនាគតរបស់សហគ្រាស) ដែលត្រូវបានទទួលស្គាល់ជាសំវិធានធន។ ឧទាហរណ៍នៃកាតព្វកិច្ចបែបនេះ គឺដូចជាចំណាយលើការពិន័យ ឬចំណាយលើការបោសសំអាត សម្រាប់ការខូចខាតដោយខុសច្បាប់ដល់បរិស្ថាន ករណីទាំងពីរនេះ នឹងនាំឱ្យមានលំហូរចេញ នៃធនធានដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ច នៅក្នុងការទូទាត់ ដោយមិនគិតពីសកម្មភាពរបស់សហគ្រាស នាពេលអនាគតក៏ដោយ។ ស្រដៀងគ្នានេះ សហគ្រាសមួយទទួលស្គាល់សំវិធានធនចំពោះចំណាយលើការជួសជុលឡើងវិញ នៃការរុករកប្រេង ឬស្ថានីយ៍ថាមពលនុយក្លេអែរ តាមទំហំទឹកប្រាក់ដែលសហគ្រាសត្រូវមានកាតព្វកិច្ច ដើម្បីសងនូវការខូចខាតទាំងនេះ។ ផ្ទុយទៅវិញ ដោយសារសំពាធពាណិជ្ជកម្ម ឬ តម្រូវការផ្លូវច្បាប់ សហគ្រាសអាចនឹងមានបំណង ឬ ចាំបាច់អនុវត្ត

ចំណាយ ដើម្បីធ្វើកិច្ចប្រតិបត្តិការអាជីវកម្មតាមរបៀបជាក់លាក់មួយ នាពេលអនាគត (ជាឧទាហរណ៍ ការដាក់ឧបករណ៍បឺតផ្សែងនៅក្នុងរោងចក្រមួយ)។ ដោយហេតុថា សហគ្រាសអាចជៀសវាងបាននូវចំណាយនាពេលអនាគត តាមរយៈសកម្មភាពនាពេលអនាគតរបស់ខ្លួន ឧទាហរណ៍ ដូចជាតាមរយៈការផ្លាស់ប្តូរនូវវិធីកិច្ចប្រតិបត្តិការ សហគ្រាសពុំមានកាតព្វកិច្ចបច្ចុប្បន្នចំពោះការចំណាយនាពេលអនាគតនោះទេ ហើយសំវិធានធនក៏មិនត្រូវបានគេទទួលស្គាល់ដែរ ។

២០ កាតព្វកិច្ចមួយ តែងតែទាក់ទងនឹងភាគីមួយទៀត ដែលសហគ្រាសជំពាក់កាតព្វកិច្ចនេះ។ ទោះជាយ៉ាងនេះក្តីវាមិនចាំបាច់ ដើម្បីស្គាល់អត្តសញ្ញាណរបស់ភាគី ដែលសហគ្រាសជំពាក់កាតព្វកិច្ចនោះទេ ពិតមែនហើយថាកាតព្វកិច្ចអាចមានទំហំធំចំពោះសាធារណៈជន។ ដោយសារកាតព្វកិច្ចតែងតែទាក់ទងទៅនឹង ការសន្យាចំពោះភាគីមួយទៀត វានាំឱ្យការអនុវត្តតាម សេចក្តីសំរេចរបស់គណៈគ្រប់គ្រង ឬក្រុមប្រឹក្សាភិបាល នឹងមិនបណ្តាល ឱ្យកើតមាននូវបំណុលប្រយោល នៅចុងការិយបរិច្ឆេទ លើកលែងតែសេចក្តីសំរេចចិត្តនោះកើតមានមុនចុងការិយបរិច្ឆេទចំពោះការសំរេចចិត្ត ដែលបានប៉ះពាល់ដោយកាតព្វកិច្ចនៅក្នុងឥរិយាបទជាក់លាក់មួយដើម្បីបង្កើនការរំពឹងទុកដ៏មាន សុពលភាពនៅក្នុងកាតព្វកិច្ច ដែលអង្គភាពនឹងទទួលខុសត្រូវ ។

២១ ព្រឹត្តិការណ៍មួយដែលមិននាំឱ្យកើនឡើងចំពោះកាតព្វកិច្ចមួយភ្លាមៗ អាចធ្វើដូច្នេះបាននៅកាលបរិច្ឆេទ ដោយសារតែការផ្លាស់ប្តូរនៅក្នុងច្បាប់ ឬដោយសារសកម្មភាព (ឧទាហរណ៍ របាយការណ៍ ជាសាធារណៈជាក់

លាក់) ដោយអង្គភាពផ្តល់ នូវការកើនឡើង នូវកាតព្វកិច្ចប្រយោល។ ឧទាហរណ៍ នៅពេលដែលការខូចខាតផ្នែកបរិស្ថានត្រូវបានបង្កឡើងអាចនឹងមិនមានកាតព្វកិច្ចត្រៀមបង្ការវិបាក ។ ទោះបីជាយ៉ាងណាក៏ដោយការធ្វើឱ្យខូចខាតនេះនឹងក្លាយជា ព្រឹត្តិការណ៍មានកាតព្វកិច្ច នៅពេលដែលច្បាប់ថ្មីតម្រូវកាតខូចខាតកំពុងកើតមានត្រូវកែតម្រូវ ឬនៅពេលដែលអង្គភាពទទួលយក ការទទួលខុសត្រូវជាសាធារណៈ សម្រាប់ការកែសម្រួល នៅក្នុងរបៀបដែលបង្កើតឡើងនូវកាតព្វកិច្ច ប្រយោល ។

២២ នៅពេលដែលសេចក្តីលម្អិតនៃច្បាប់ថ្មីដែលបានស្នើឡើងនៅ ពុំទាន់បានបញ្ចប់នៅឡើយ នោះកាតព្វកិច្ចកើតឡើងតែពេលមួយគត់ដែលច្បាប់នោះច្បាស់ជានឹងត្រូវបានអនុម័តជាច្បាប់ពង្រាង។ សម្រាប់គោលបំណង នៃស្តង់ដានេះ កាតព្វកិច្ច បែបនេះ ត្រូវបានចាត់ទុកថា ជាកាតព្វកិច្ចតាមផ្លូវច្បាប់។ ភាពខុសគ្នានៅក្នុងកាលៈទេសៈជុំវិញការអនុមត័នេះ មិនអាចធ្វើការបញ្ជាក់ពីព្រឹត្តិការណ៍តែមួយបានទេ ដែលនឹងអាចធ្វើការអនុមត័ច្បាប់នេះ មានភាពច្បាស់លាស់។ ក្នុងករណីភាគច្រើន វាមិនអាចច្បាស់លាស់ទាំងស្រុង ពីការអនុម័តឱ្យប្រើប្រាស់ច្បាប់មួយ រហូតដល់ពេលណាដែលច្បាប់នោះត្រូវបានអនុម័ត ។

## លំហូរចេញនូវធនធានដែលទំនងនឹងកើតមានឡើងដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ច

២៣ សម្រាប់បំណុលមួយដែលបំពេញលក្ខណៈសម្បត្តិឱ្យការទទួលស្គាល់ គឺមិនត្រឹមតែកាតព្វកិច្ចបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែភវនីយភាពនៃការលំហូរ

ចេញនូវធនធាន ដែលតំណាងឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការទូទាត់នូវកាតព្វកិច្ចទាំងនោះផងដែរ។ ចំពោះគោលបំណងរបស់ស្តង់ដានេះ លំហូរចេញនូវធនធាន ឬព្រឹត្តិការណ៍ផ្សេងទៀត គឺត្រូវបានចាត់ទុកថាទំនងនឹងកើតមានឡើង ពោលគឺ ភវនីយភាពដែលព្រឹត្តិការណ៍នឹងកើតឡើងមានច្រើនជាងភវនីយភាព ដែលវានឹងមិនកើតឡើង។ នៅពេលដែលវាទំនងជាមិនអាចកើតដែលថា មានកាតព្វកិច្ចបច្ចុប្បន្ន សហគ្រាស ត្រូវលាតត្រដាង នូវបំណុលយថាហេតុ លើកលែងតែ លទ្ធភាពនៃលំហូរចេញនូវធនធានតំណាងឱ្យផលប្រយោជន៍ សេដ្ឋកិច្ចមានលក្ខណៈដាច់ស្រយាល (សូមមើលកថាខណ្ឌទី ៨៦) ។

២៤ នៅពេលដែលមានកាតព្វកិច្ចមួយចំនួនស្រដៀងគ្នា (ឧទាហរណ៍ ការធានាលើផលិតផល ឬកិច្ចសន្យាស្រដៀងគ្នា) ភវនីយភាពដែលលំហូរចេញ នូវធនធានត្រូវបានតម្រូវឲ្យមានដើម្បីទូទាត់កាតព្វកិច្ច ត្រូវបានកំណត់ដោយធ្វើការពិចារណារួម នូវបំណុលទាំងមូលនោះ។ បើទោះជាភាពដែលកើតមានឡើងនៃលំហូរចេញនៃធាតុមួយអាចមានលក្ខណៈតូចតាច វាអាចប្រហាក់ទំនងថាដែលថា លំហូរចេញមួយចំនួននៃធនធាន នឹងត្រូវការដើម្បី ទូទាត់បំណុលនោះទាំងមូល។ ក្នុងករណីនេះ សំវិធានធនត្រូវបានទទួលស្គាល់ (បើសិនវាបំពេញបានលក្ខខណ្ឌវិនិច្ឆ័យផ្សេងទៀត សម្រាប់ទទួលស្គាល់វា)។

### ការប៉ាន់ស្មានបំណុលដែលគួរឱ្យទុកចិត្តបាន

២៥ ការប្រើប្រាស់ការប៉ាន់ស្មាន គឺជាផ្នែកដ៏សំខាន់មួយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយវាមិនធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់លើរបាយការណ៍របស់ពួកគេឡើយ ។ ចំណុចនេះកាន់តែ ច្បាស់ទៅទៀត នៅក្នុងករណីសំវិធានធន ដោយសារលក្ខណៈរបស់វាមានភាពមិនច្បាស់លាស់ជាងធាតុផ្សេងៗទៀត នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ លើកលែងតែក្នុងករណីដ៏កំរមួយចំនួន សហគ្រាសមួយនឹងមានលទ្ធភាពកំណត់នូវទិន្នផល ដែលអាចកើតមានមួយចំនួន ហេតុដូច្នេះហើយ ទើបអាចធ្វើការប៉ាន់ស្មានកាតព្វកិច្ចដែលអាច ជឿទុកចិត្តបានសម្រាប់ការប្រើប្រាស់ក្នុងការទទួលស្គាល់នូវសំវិធានធនមួយ ។

២៦ នៅក្នុងករណីដ៏កម្រមួយចំនួន ដែលមិនមានការប៉ាន់ស្មានអាចគួរឱ្យទុកចិត្តបាន នោះបំណុលដែលកើតមានឡើងមិនអាចទទួលស្គាល់បានឡើយ។ បំណុលនោះ ត្រូវបានលាតត្រដាងបង្ហាញ ជាបំណុលយថាហេតុ (សូមមើលកថាខណ្ឌ ៨៦) ។

### បំណុលយថាហេតុ

**២៧ សហគ្រាសមិនត្រូវទទួលស្គាល់ នូវបំណុលយថាហេតុឡើយ ។**

២៨ ត្រូវលាតត្រដាងពីបំណុលយថាហេតុ ដូចបានតម្រូវដោយកថាខណ្ឌ៨៦ លើកលែងតែភវនីយភាពនៃលំហូរចេញនូវធនធានតំណាងឱ្យ ផលប្រយោ-ជន៍សេដ្ឋកិច្ចមានលក្ខណៈស្រពិចស្រពិល ។

២៩ នៅពេលដែលសហគ្រាសមួយទទួលខុសត្រូវរួម និងច្រើន ផ្នែកនៃកាតព្វកិច្ចដែលត្រូវបានរំពឹងថា ភាគីដទៃទៀត ត្រូវបានចាត់ទុកជាបំណុលយថាភាព។ សហគ្រាសត្រូវទទួលស្គាល់នូវសំវិធានធនសម្រាប់ផ្នែកនៃកាតព្វកិច្ច ដែលលំហូរចេញនូវធនធាន តំណាងឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចទំនង ជាកើតមានឡើង លើកលែងតែក្នុងកាលៈទេសៈដ៏កម្រមួយចំនួនដែល មិនអាចធ្វើការប៉ាន់ស្មានគួរឱ្យទុកចិត្តបាន។

៣០ បំណុលយថាហេតុអាចបង្កើតតាមរបៀបមួយ ដែលមិនត្រូវបានរំពឹងទុកពេលដំបូង។ ដូច្នេះ បំណុល ត្រូវបានវាយតំលៃជាបន្ត ដើម្បីកំណត់ថាតើលំហូរចេញនៃធនធាន ដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច បានក្លាយជាភវនីយភាពដែរ ឬអត់។ ប្រសិនបើវាទំនងថាការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច

ត្រូវបានតម្រូវឱ្យមានសម្រាប់ធាតុមួយដែលជាប់ទាក់ទងពីមុន ជាបំណុលថាហេតុ នោះសំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃគ្រា ដែលការផ្លាស់ប្តូរ ភវនីយភាពកើតឡើង (លើកលែងតែនៅក្នុងកាលៈទេសៈដ៏កម្រ ដែលមិនមានការប៉ាន់ស្មានដែលអាចគួរឱ្យជឿជាក់បាន)។

## ទ្រព្យសកម្មយថាហេតុ

### ៣១ អង្គភាពមួយមិនត្រូវទទួលស្គាល់ទ្រព្យសកម្មយថាហេតុ

៣២ ទ្រព្យសកម្មយថាហេតុជាធម្មតាកើតឡើងពីព្រឹត្តិការណ៍មិនបានគ្រោងទុក ឬ ព្រឹត្តិការណ៍មិនបានរំពឹងទុកដែល នាំឱ្យបានកើនឡើងចំពោះភាពអាច

កើតឡើងនៃលំហូរចូលអត្ថប្រយោជន៍សេដ្ឋកិច្ចមកអង្គភាព។ ឧទាហរណ៍មួយគឺការទាមទារដែលអង្គភាពប្តឹងតាមរយៈផ្លូវច្បាប់ ដែលលទ្ធផលមានភាពមិនច្បាស់លាស់។

៣៣ ទ្រព្យសកម្មយថាហេតុ មិនត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយសារវាអាចនាំឱ្យការទទួលចំណូលដែលមិនត្រូវបានទទួលស្គាល់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលការទទួលស្គាល់ចំណូលមានភាពប្រាកដប្រជា ក្រោយមកទ្រព្យសកម្មទាក់ទិនគឺមិនមែនជាទ្រព្យសកម្មយថាហេតុ និងការទទួលស្គាល់របស់វាមានភាពសមស្រប។

៣៤ ទ្រព្យសកម្មយថាហេតុត្រូវបានលាតត្រដាងដូចបានតម្រូវនៅក្នុងកថាខណ្ឌ ៨៩ នៅពេលដែលលំហូរចូលនៃ អត្ថប្រយោជន៍សេដ្ឋកិច្ចមានភវនីយ-ភាព ។

៣៥ ទ្រព្យសកម្មយថាហេតុត្រូវបានវាយតំលៃជាបន្តដើម្បីធានាថាការអភិវឌ្ឍត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើវាមានភាពប្រាកដប្រជាដែលលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច នឹងកើនឡើងទ្រព្យសកម្ម និងចំណូលទាក់ទិន ត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុនៃការិយ បរិច្ឆេទដែលការផ្លាស់ប្តូរកើតឡើង។ ប្រសិនបើលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចមានភវនីយភាព អង្គភាពលាតត្រដាងទ្រព្យសកម្មយថាហេតុ (សូមមើលកថាខណ្ឌ ៨៩) ។

**ការប៉ាន់ស្មានដ៏ល្អបំផុត**

៣៦ **ទឹកប្រាក់ដែលបានទទួលស្គាល់ជាសំវិធានធនត្រូវតែជាការប៉ាន់ ស្មានដ៏ល្អបំផុតនៃការចំណាយដែលបានតម្រូវឱ្យមានដើម្បីទូទាត់កាតព្វកិច្ចបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។**

៣៧ ការប៉ាន់ស្មានដ៏ល្អបំផុត នៃការចំណាយ ដែលបានតម្រូវ ដើម្បីទូទាត់កាតព្វកិច្ចបច្ចុប្បន្នគឺជាទឹកប្រាក់ ដែលអង្គភាពមួយនឹងសង ដើម្បីទូទាត់កាតព្វកិច្ចនៅចុងការិយបរិច្ឆេទរាយការណ៍ ឬនឹងត្រូវផ្ទេរវាទៅភាគីទី ៣ នៅពេលនោះ។ វានឹងមិនអាចទៅរួចទេ ឬវានឹងចំណាយអស់ច្រើនដើម្បីទូទាត់ ឬផ្ទេរកាតព្វកិច្ចនៅចុងការិយ បរិច្ឆេទរាយការណ៍។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មានពីទឹកប្រាក់ដែលអង្គភាពមួយអាចនឹងបង់ដើម្បីទូទាត់ ឬដើម្បីផ្ទេរកាតព្វកិច្ច ផ្តល់នូវការប៉ាន់ស្មានដ៏ល្អបំផុតនៃចំណាយ ដែលបានតម្រូវឱ្យមាន ដើម្បីទូទាត់កាតព្វកិច្ចបច្ចុប្បន្ននៅចុងការិយបរិច្ឆេទរាយការណ៍។

៣៨ ការប៉ាន់ស្មាននៃលទ្ធផល និងឥទ្ធិពលហិរញ្ញវត្ថុត្រូវបានកំណត់ ដោយការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងរបស់ អង្គភាព បន្ថែមដោយបទពិសោធន៍ពីប្រតិបត្តិការប្រហាក់ប្រហែលគ្នា និងនៅក្នុងករណីខ្លះ របាយការណ៍ពីអ្នកជំនាញឯករាជ្យ។ ភស្តុតាងដែលបានពិចារណារួមបញ្ចូលនូវភស្តុតាងបន្ថែមដែលបានផ្តល់ដោយព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

៣៩ ភាពមិនច្បាស់លាស់ដែលទាក់ទិននឹងទឹកប្រាក់ដែលត្រូវបាន ទទួលស្គាល់ជាសំវិធានធនត្រូវបានដោះស្រាយ ដោយមធ្យោបាយផ្សេងៗ ដោយយោងទៅតាមកាលៈទេសៈ។ នៅពេលដែលសំវិធានធនដែលបានវាស់វែងជាប់ទាក់ទិននឹងចំនួនសរុបនៃធាតុ នោះកាតព្វកិច្ចត្រូវបានប៉ាន់ស្មាន ដោយថ្លឹងជាមធ្យមនូវលទ្ធផលដែល អាចកើតឡើងទាំងអស់ដោយភវនីយភាព ជាប់ពាក់ព័ន្ធរបស់គេ។ ឈ្មោះសម្រាប់វិធីសាស្ត្រស្ថិតិនៃការប៉ាន់ស្មាន នេះគឺជា "តំលៃរំពឹង"។ ដូច្នេះ សំវិធានធននឹងខុសពីគ្នាអាស្រ័យលើថាតើ ភវនីយ-ភាពនៃការខាតនៃទឹកប្រាក់ដឹងបាន គឺ ឧទាហរណ៍ ៦០ ភាគរយ ឬ ៩០ ភាគរយ។ នៅពេលដែលមានកំរិតនៃលទ្ធផលអាចកើត មានជាបន្ត និងចំណុចនីមួយៗនៅក្នុងចន្លោះនោះ គឺដូចនឹងចំណុចផ្សេងទៀតចំណុចកណ្តាលនៃចន្លោះ ត្រូវបានប្រើ។

| |
|---|
| ឧទាហរណ៍ ៖<br>សហគ្រាសមួយ លក់ទំនិញឱ្យអតិថិជនដោយធានាថា សហគ្រាស នឹងធានាលើចំណាយជួសជុល សម្រាប់ការខូចខាតពីរោងចក្រ ក្នុងរយៈពេល ៦ខែ ដំបូងបន្ទាប់ពីការទិញទំនិញ។ ប្រសិនបើរកឃើញថា មានការខូចខាតតិចតួចក្នុងផលិតផល ដែលបានលក់ចេញ នឹងនាំឱ្យមានចំណាយជួសជុលអស់តំលៃ ១លានដុល្លា។ តែប្រសិនរកឃើញថា មានការខូចខាតខ្លាំងក្នុងផលិតផល ដែលបានលក់ចេញនោះ នឹងនាំឱ្យមានចំណាយ ជួសជុលមានតំលៃរហូតដល់៤លានដុល្លារ។ ឆ្លងតាមបទពិសោធន៍កន្លងមក និង |

ការរំពឹងទុកនាពេលអនាគតរបស់សហគ្រាស បង្ហាញឱ្យឃើញថា សម្រាប់ប៉ុន្មានឆ្នាំខាងមុខនេះ ៧៥% នៃផលិតផលបានលក់ នឹងគ្មានការខូចខាតទេ ហើយ ២០% នៃផលិតផលបានលក់ មានការខូតខាតតិចតួច និង៥% ទៀតមានការខូតខាតខ្លាំង។ អនុលោមទៅតាមកថាខណ្ឌទី ២៤ សហគ្រាស ត្រូវធ្វើការវាយតំលៃភាពទំនង នៃលំហូរចេញ នៃធនធានសម្រាប់ បំណុលធានាទាំងមូល។ តំលៃរំពឹងទុកនៃថ្លៃជួសជុស គឺ ÷
(៧៥%នៃសូន្យ) + (២០% នៃ ១លាន ) + (៥% នៃ ៤លាន ) = ៤០០.០០០

៤០ នៅពេលដែលកាតព្វកិច្ចទោលមួយត្រូវបានវាស់វែង ទិន្នផលមួយទំនងយកមកធ្វើជាខ្នាតសម្រាប់ការប៉ាន់ស្មានដ៏ប្រសើរបំផុតនៃបំណុល។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងករណីបែបនេះ សហគ្រាសត្រូវធ្វើការពិចារណាលើទិន្នផលដែលអាចកើតមានឡើងដទៃទៀតដែរ។ នៅពេលដែលទិន្នផលដទៃទៀតអាចកើតមានឡើង មានតម្លៃខ្ពស់ជាងខ្លាំង ឬ ទាបជាងខ្លាំង ទិន្នផលដែលទំនងជាកើតឡើងបំផុតនោះ គឺជាការប៉ាន់ស្មានដ៏ប្រសើរបំផុត ចំពោះចំនួនទឹកប្រាក់ដែលខ្ពស់ជាង ឬដែលទាបជាងទាំងនោះ។ ឧទាហរណ៍ ប្រសិនបើសហគ្រាសត្រូវការកែតម្រូវកំហុសកើតឡើងក្នុងរោងចក្រដ៏សំខាន់មួយ ដែលបានសាងសង់ឱ្យអតិថិជនទិន្នផលមួយទំនងជាកើតឡើងបំផុត គឺប្រហែលជាសម្រាប់ការជួសជុលក្នុងតំលៃ ១.០០០ ដើម្បីជោគជ័យក្នុងការប្រឹងប្រែងលើកដំបូង ប៉ុន្តែសំវិធានធន

ក្នុងចំនួនទឹកប្រាក់ច្រើនជាង ១.០០០ នឹងត្រូវបានធ្វើឡើង ប្រសិនបើមានឱកាសសំខាន់ៗដែលថា ការប្រឹងប្រែងផ្សេងទៀតមានភាពចាំបាច់ ។

៤១ ព្រោះតែផលវិបាកខាងសារពើពន្ធលើសំវិធានធន និងបម្រែបម្រួលរបស់វា សំវិធានធនត្រូវបានវាស់វែងមុនគិតពន្ធ ត្រូវបានកំណត់ក្នុងស្តង់ដា ស.គ.អ.ក ១២ ពន្ធលើប្រាក់ចំណូល។

## ហានិភ័យ និង ភាពមិនច្បាស់លាស់

**៤២ ហានិភ័យ និងភាពមិនច្បាស់លាស់ដែលមិនអាចជៀសវាងបាននៅជុំវិញព្រឹត្តិការណ៍ និងកាលៈទេសៈនានា តែត្រូវលើកយកមកពិចារណា ដើម្បីសំរេចបាននូវតំលៃប៉ាន់ស្មានប្រសើរបំផុត នៃសំវិធានធន ។**

៤៣- ហានិភ័យ ពិពណ៌នាអំពីភាពផ្លាស់ប្តូរនៃទិន្នផល។ ការកែតម្រូវហានិភ័យអាចបង្កើនបំណុល ដែលបានវាស់វែង។ ត្រូវប្រយ័ត្ន នៅក្នុងការធ្វើការវិនិច្ឆ័យពីលក្ខខណ្ឌនៃភាពមិនច្បាស់លាស់ ដូច្នេះ ចំណូលឬទ្រព្យសកម្មមិនត្រូវបានបង្ហាញលើស ហើយចំណាយ និងទ្រព្យបំណុល ក៏មិនត្រូវបានបង្ហាញខ្វះដែរ។ ទោះបីយ៉ាងណាក៏ដោយភាពមិនច្បាស់លាស់មិនត្រូវយកមកធ្វើជាហេតុផល នៃការបង្កើតសំវិធានធន ដែលធំហួសហេតុ ឬការបង្ហាញលើស ដោយចេតនាពីបំណុលឡើយ។ ឧទាហរណ៍ ប្រសិនបើចំណាយដែលបានគ្រោងទុក នៃទិន្នផលមិនគួរជាទីពេញចិត្តណាមួយត្រូវបានគេប៉ាន់ស្មាន តាមគោលការណ៍ប្រុងប្រយ័ត្ន បន្ទាប់មកទិន្នផលនោះមិនត្រូវបានចាត់ទុកដោយចេតនាថា អាចកើតមានឡើងច្រើន ជាងករណីពិតប្រាកដឡើយ។ ការយកចិត្តទុកដាក់មានភាពចាំបាច់ដើម្បីជៀសវាង

នូវការកែសម្រួលជាន់គ្នាសម្រាប់ហានិភ័យ និងភាពមិនច្បាស់លាស់ជាមួយការបង្ហាញលើសវិបាកនៃសំវិធានធន។

៤៤ ការលាតត្រដាងបង្ហាញ ពីភាពមិនច្បាស់លាស់ ដែលនៅជុំវិញទឹកប្រាក់ចំណាយ ត្រូវធ្វើឡើងតាមកថាខណ្ឌ ៨៥ (ខ) ។

**តំលៃបច្ចុប្បន្ន**

**៤៥ នៅពេលដែលផលប៉ះពាល់នៃតម្លៃពេលវេលានៃប្រាក់ មានលក្ខណៈជាសារវ័ន្ត ទឹកប្រាក់នៃសំវិធានធន ត្រូវតែជាតំលៃលបច្ចុប្បន្ន នៃចំណាយដែលរំពឹងទុកដែលត្រូវបានតម្រូវឱ្យមានដើម្បីទៅទូទាត់កាតព្វកិច្ច។**

៤៦ ដោយសារតែតំលៃពេលវេលានៃប្រាក់ សំវិធានធានពាក់ព័ន្ធនឹងលំហូរចេញនៃសាច់ប្រាក់ដែលកើតឡើងឆាប់ៗ បន្ទាប់ការិយបរិច្ឆេទរាយការណ៍មានការខាតបង់ជាង សំវិធានធនពាក់ព័ន្ធនឹងលំហូរចេញនៃទឹកប្រាក់ដែលមានតំលៃស្មើគ្នាកើតឡើងនៅពេលក្រោយ។ ដូច្នេះ សំវិធានធានត្រូវបានធ្វើអប្បហារនៅពេលដែលផលប៉ះពាល់មានលក្ខណៈជាសារវ័ន្ត។

**៤៧ អត្រាអប្បហារ (ឬ អត្រា ) ត្រូវតែជាអត្រាមុនគិតពន្ធ (ឬ អត្រា ) ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃ តាមទីផ្សារបច្ចុប្បន្ន នៃតំលៃពេលនៃប្រាក់ និងហានិភ័យពាក់ព័ន្ធយ៉ាងជាក់លាក់ ចំពោះបំណុលនេះ។ អត្រាអប្បហាមួយ (ឬច្រើន) មិនឆ្លុះបញ្ចាំងពីហានិភ័យលើការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគត ដែលត្រូវបានគេធ្វើនិយ័តភាពឡើយ។**

**ព្រឹត្តិការណ៍អនាគត**

**៤៨ ព្រឹត្តិការណ៍អនាគតដែលអាចប៉ះពាល់ទឹកប្រាក់ដែលតម្រូវឱ្យទូទាត់កាតព្វកិច្ច ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទឹកប្រាក់ នៃសំវិធានធនដែលមានភស្តុតាង គ្រប់គ្រាន់ដែលពួកគេនឹងកើតឡើង។**

៤៩ ព្រឹត្តិការណ៍អនាគតដែលរំពឹងថានឹងកើតមានឡើង អាចមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់វាស់វែងសំវិធានធន។ ឧទាហរណ៍ សហគ្រាសមួយប្រហែលជាជឿថា ចំណាយសំអាតទីតាំងមួយនៅពេលបញ្ចប់របស់វាត្រូវបានកាត់បន្ថយដោយសារការផ្លាស់ប្តូរបច្ចេកវិទ្យានាពេលអនាគត។ តម្លៃដែលទទួលស្គាល់នេះឆ្លុះបញ្ចាំងពី ការរំពឹងទុកដ៏សមហេតុផលមួយរបស់អ្នកសង្កេតការណ៍ប្រកបដោយ លក្ខណៈសត្យានុម័ត និងប្រកបដោយលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ ដែលអ្នកសង្កេតការណ៍នេះបានលើកយកមកពិចារណា នូវភស្តុតាងទាំងអស់ ដែលទាក់ទងនឹងបច្ចេកវិទ្យាដែលនឹងមាននៅពេលសំអាតទីតាំងនោះ។ ដូច្នេះ វាជាការត្រឹមត្រូវក្នុងការរួមបញ្ចូល ឧទាហរណ៍ ការកាត់បន្ថយចំណាយ ដែលរំពឹងថាដោយសារការកើនឡើង នៃបទពិសោធន៍ក្នុងការប្រើប្រាស់បច្ចេកទេសដែលមានស្រាប់ ឬចំណាយដែលរំពឹងទុកនៅក្នុងការប្រើប្រាស់បច្ចេកទេសដែលមានស្រាប់ ដោយទ្រង់ទ្រាយធំ ឬស្មុគស្មាញជាងមុននៅក្នុងប្រតិបត្តិការសំអាតពីពេលមុន។ទោះជាយ៉ាងនេះក្តី សហគ្រាសមិនត្រូវរំពឹងទុកនូវការអភិវឌ្ឍបច្ចេកវិទ្យាថ្មី ទាំងស្រុង សម្រាប់ការសំអាតទីតាំងនោះទេលើកលែងតែ សហគ្រាសមានភស្តុតាងគ្រប់គ្រាន់ ។

៥០ ផលប៉ះពាល់ពីលទ្ធភាពបង្កើតនីតិថ្មី ត្រូវបានយកមកពិចារណានៅក្នុងការវាស់វែងបំណុល ដែលមានស្រាប់មួយ នៅពេលដែលមានភស្តុតាងគ្រប់គ្រាន់ថា នីតិគឺនិងត្រូវបានអនុម័តពិតប្រាកដមែន ។ កាលៈទេសៈផ្សេងគ្នាកើតឡើងដែលធ្វើឱ្យយើងមិនអាចកំណត់បានចំពោះតែព្រឹត្តិការណ៍តែមួយឱ្យមានភាពគ្រប់គ្រាន់ ចំពោះភស្តុតាងទាំងអស់ ក្នុងគ្រប់ករណីបានទេ។ ភស្តុតាងបានទាមទារឱ្យមានទាំងអស់ នូវអ្វីដែលជាសេចក្តីត្រូវការរបស់នីតិកម្ម ហើយថាតើវាប្រាកដជាត្រូវបានអនុម័តឱ្យប្រើ និងបានយកទៅអនុវត្តតាម ការកំណត់ដែរឬទេ។ ក្នុងករណីភាគច្រើន ភស្តុតាងដែលគ្រប់គ្រាន់ នឹងមិនមានទេរហូតទាល់តែនីតិកម្មថ្មី ត្រូវបានអនុម័ត ។

## ការលក់ទ្រព្យសកម្មដែលបានរំពឹងទុក

៥១ ចំណេញពីការលក់ទ្រព្យសកម្ម ដែលបានរំពឹងទុក មិនត្រូវបានយកមកពិចារណាក្នុងការវាស់វែងសំវិធានធនឡើយ ។

៥២ ចំណេញលើការលក់ទ្រព្យសកម្មដែលបានរំពឹងទុក មិនត្រូវបានយកមកពិចារណានៅក្នុងការវាស់វែងសំវិធានធនឡើយ ទោះបីជាការលក់ ដែលបានរំពឹងទុកនោះ មានទំនាក់ទំនងយ៉ាងជិតដិតនឹងព្រឹត្តិការណ៍ដែលនាំឱ្យមានការកើនឡើងនូវសំវិធានធននោះក៏ដោយ។ ជំនួសមកវិញ សហគ្រាសមួយនឹងទទួលស្គាល់ផលចំណេញដែលបានរំពឹងទុកពីការលក់ទ្រព្យសកម្មនៅពេលដែលបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងស្តង់ដា ដែលចែងអំពីទ្រព្យសកម្មពាក់ព័ន្ធ ។

## សំណាង

៥៣ **នៅពេលដែលចំណាយខ្លះ ឬចំណាយទាំងអស់ដែលបានតម្រូវឱ្យទូទាត់សំវិធានធនត្រូវបានរំពឹងទុក ថានឹងសងវិញដោយភាគីមួយទៀត សំណាងត្រូវបានទទួលស្គាល់នៅពេលដែល និង តែនៅពេលដែល វាប្រាកដថាសំណាងនឹងត្រូវបានទទួលប្រសិនបើអង្គភាពទូទាត់កាតព្វកិច្ច។ សំណាងត្រូវបានចាត់ទុក ជាទ្រព្យសកម្មដាច់ដោយឡែក។ ទឹកប្រាក់ដែលបានទទួលស្គាល់សម្រាប់សំណាងមិនត្រូវលើសចំនួន ទឹកប្រាក់ នៃសំវិធានធនឡើយ។**

៥៤ **នៅក្នុងរបាយការណ៍លទ្ធផលលម្អិត ចំណាយដែលទាក់ទិននឹងសំវិធានធនអាចត្រូវបានដាក់បង្ហាញ តាមទឹកប្រាក់ពិតដែលបានទទួលស្គាល់សម្រាប់សំណាង។**

៥៥ ពេលខ្លះ សហគ្រាសមួយ គឺអាចមានលទ្ធភាពស្វែងរកភាគីដទៃទៀតដើម្បីទូទាត់ចំណាយទាំងអស់ឬក៏ផ្នែកខ្លះដែលត្រូវការដើម្បីទូទាត់សំវិធានធនមួយ (ជាឧទាហរណ៍ដូចជាតាមរយៈកិច្ចសន្យាធានារ៉ាប់រងអនុប្រយោគការពារ ឬការធានារបស់អ្នកផ្គត់ផ្គង់)។ ភាគីដទៃទៀត អាចសងប្រាក់ ដែលបានបង់ដោយសហគ្រាស ឬក៏សងទឹកប្រាក់ទាំងនោះដោយផ្ទាល់ខ្លួន។

៥៦ នៅក្នុងករណីភាគច្រើន សហគ្រាសនឹងនៅតែទទួលខុសត្រូវ ចំពោះចំនួនទឹកប្រាក់សរុប ដែលស្ថិតនៅក្នុងការសង្ស័យ ដូច្នេះសហគ្រាស នឹងត្រូវទូទាត់ចំនួនសរុប ប្រសិនបើភាគីទីបីខកខានពុំបានសង ដោយសារមូលហេតុណាមួយ។ ក្នុងស្ថានភាពបែបនេះ សំវិធានធនមួយត្រូវបានទទួលស្គាល់ សម្រាប់ចំនួនទឹកប្រាក់បំណុលពេញលេញ ហើយទ្រព្យសកម្មដាច់ដោយឡែកសម្រាប់ការទូទាត់សងវិញដែលបានរំពឹងទុក គឺត្រូវបានទទួល

ស្គាល់នៅពេលដែលវាច្បាស់លាស់ថា ការទូទាត់សងវិញនឹងបានទទួល ប្រសិនបើសហគ្រាសទូទាត់បំណុលរបស់ខ្លួន ។

៥៧ ក្នុងករណីខ្លះ សហគ្រាសនឹងមិនមានការទទួលខុសត្រូវ ចំពោះចំណាយដែលស្ថិតនៅក្នុងការសង្ស័យ ប្រសិនបើ ភាគីទីបីខកខានពុំបានសង។ ក្នុងករណីបែបនេះ សហគ្រាសពុំមាន ការទទួលខុសត្រូវ ចំពោះការចំណាយទាំងនោះទេ ហើយចំណាយទាំងនោះ ពុំត្រូវបានរួមបញ្ចូលក្នុងសំវិធានធនផងដែរ ។

៥៨ ដូចដែលបានបង្ហាញក្នុងកថាខណ្ឌទី២៩ កាតព្វកិច្ចដែលសហគ្រាសមួយមានការទទួលខុសត្រូវរួមគ្នា និងច្រើនគ្នាជាបំណុលយថាហេតុ ទៅតាមទំហំទឹកប្រាក់ដែលត្រូវបានរំពឹងថាកាតព្វកិច្ចនឹងត្រូវបានទូទាត់ដោយភាគីដទៃទៀត ។

## ការផ្លាស់ប្តូរសំវិធានធន

**៥៩ សំវិធានធន ត្រូវបានពិនិត្យឡើងវិញ នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានធ្វើនិយ័តភាពដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានប្រសើរបំផុតនាពេលបច្ចុប្បន្ន។ ប្រសិនបើវាពុំទំនងថា លំហូរចេញមួយនៃធនធានដែលតំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ច នឹងត្រូវបានតម្រូវដើម្បីទៅជិះបំណុលទេនោះ ដូចនេះសំវិធានធននោះ ត្រូវបានកត់ត្រាបញ្រ្ចាស់មកវិញ។**

៦០ នៅពេលដែលអប្បហារត្រូវបានប្រើប្រាស់តម្លៃយោងនៃសំវិធានធនមួយកើនឡើងនៅក្នុងការិយបរិច្ឆេទនីមួយៗ ដើម្បីឆ្លុះបញ្ចាំងអំពីការកន្លងផុត

ទៅនៃពេលវេលា។ ហើយការកើនឡើងនេះត្រូវបានទទួលស្គាល់ជាបន្ទុកលើប្រាក់កម្ចី។

## ការប្រើប្រាស់សំវិធានធន

**៦១ សំវិធានធន ត្រូវបានប្រើប្រាស់តែចំពោះការចំណាយដែលសំវិធានធន ត្រូវបានទទួលស្គាល់លើកដំបូងប៉ុណ្ណោះ។**

៦២ មានតែចំណាយដែលទាក់ទិននឹងសំវិធានធនលើកដំបូងប៉ុណ្ណោះ ដែលត្រូវបានកាត់កង ។ ការកំណត់ចំណាយ ទល់នឹងសំវិធានធន ដែលត្រូវបានទទួលស្គាល់លើកដំបូងសម្រាប់គោលបំណងផ្សេងទៀត អាចបិទបាំងពីផល ប៉ះពាល់នៃព្រឹត្តិការណ៍ខុសៗគ្នាចំនួនពីរ។

## ការអនុវត្តច្បាប់នៃការទទួលស្គាល់ និងការវាស់វែង

### ការខាតពីកិច្ចប្រតិបត្តិការអនាគត

**៦៣ សំវិធានធនមិនត្រូវបានទទួលស្គាល់សម្រាប់ការខាតពីកិច្ចប្រតិបត្តិការ នាពេលអនាគត។**

៦៤ ការខាតពីកិច្ចប្រតិបត្តិការអនាគតមិនបំពេញនិយម នៃបំណុលនៅក្នុងកថាខណ្ឌ ១០ និងលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់ជាទូទៅ ដែលបានកំណត់នៅក្នុងកថាខណ្ឌ ១៤។

៦៥ ការរំពឹងទុកនៃការខាតពីកិច្ចប្រតិបត្តិការអនាគតគឺជាបង្ហាញថាទ្រព្យសកម្ម ជាក់លាក់នៃកិច្ចប្រតិបត្តិការអាច ត្រូវបានធ្លាក់ចុះតំលៃ។ សហគ្រាសមួយ

ធ្វើតេស្តពីទ្រព្យកម្មទាំងនេះសម្រាប់ការធ្លាក់ចុះតំលៃក្រោម ស.គ.អ.ក ៣៦ *ការធ្លាក់ចុះតំលៃនៃទ្រព្យសកម្ម។*

**កិច្ចសន្យាដែលនាំឱ្យមានការខាតបង់**

**៦៦ ប្រសិនបើសហគ្រាស មានកិច្ចសន្យាមួយ ដែលនាំឱ្យមានការខាតបង់ បំណុលនាពេលបច្ចុប្បន្នតាមកិច្ចសន្យា នោះត្រូវតែបានវាស់វែង និង ទទួលស្គាល់ថាជាសំវិធានធន។**

៦៧ កិច្ចសន្យាជាច្រើន (ជាឧទាហរណ៍ ដូចជាការបញ្ជាទិញជាធម្មតាខ្លះ) អាចត្រូវបានលុបចោលដោយពុំបង់ថ្លៃតបស្នងទៅឲ្យភាគីផ្សេងទៀត ដូច្នេះហើយ វាពុំមានកាតព្វកិច្ចទេ។ កិច្ចសន្យាដទៃទៀត បង្កើតទាំងសិទ្ធិ និង កាតព្វកិច្ចសម្រាប់ភាគីដែលបានចុះកិច្ចសន្យានីមួយៗ។ នៅពេលដែលព្រឹត្តិការណ៍ទាំងឡាយ ដែលធ្វើឱ្យកិច្ចសន្យាទាំងនោះ ក្លាយជាកិច្ចសន្យាដែលនាំឱ្យមានការខាតបង់នោះ កិច្ចសន្យានោះ នឹងស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដានេះ ហើយបំណុលដែលមានស្រាប់ត្រូវបានទទួលស្គាល់។ កិច្ចសន្យាប្រតិបត្តិ ដែលនឹងអនុវត្តហើយមិននាំឱ្យមានការខាតបង់ គឺមិនស្ថិតនៅក្នុងវិសាលភាព នៃស្តង់ដានេះឡើយ។

៦៨ ស្តង់ដានេះឲ្យនិយមកិច្ចសន្យាដែលនាំឱ្យខាតបង់ គឺជាកិច្ចសន្យាដែលត្រូវមានការចំណាយ ដែលមិនអាចជៀសវាងបាន ដើម្បីបំពេញទៅតាមកាតព្វកិច្ចនៅក្នុងកិច្ចសន្យានេះ លើសពីផលប្រយោជន៍សេដ្ឋកិច្ចដែលរំពឹងទុកថាទទួលពីកិច្ចសន្យានោះ។ ចំណាយដែលមិនអាចជៀសវាងបាន របស់កិច្ចសន្យាមួយវាឆ្លុះបញ្ចាំង អំពីចំណាយពិតតិចបំផុត នៃការចាកចេញពីកិច្ចសន្យានេះដែលទាបជាងរវាងចំណាយដើម្បីបំពេញកិច្ចសន្យា នេះនឹង

ការសងជំងឺចិត្ត ឬការផាកពិន័យណាមួយ ដែលបានមកពីការខកខានពុំបានបំពេញតាមកិច្ចសន្យានេះ ។

៦៩ មុនពេល សំវិធានធនដាច់ដោយឡែកមួយ សម្រាប់កិច្ចសន្យា ដែលនាំឱ្យខាតបង់ត្រូវបានបង្កើតឡើង សហគ្រាសមួយត្រូវទទួលស្គាល់ ការខាតបង់ដែលកើតពីការធ្លាក់ចុះតំលៃណាមួយដែលកើតឡើងចំពោះទ្រព្យសកម្មដែលបានប្រើប្រាស់នៅក្នុងកិច្ចសន្យានោះ។ (សូមមើល ស.គ.អ.ក ៣៦ ការស្រុតចុះនៃតម្លៃទ្រព្យសកម្ម)។

## ការរៀបចំរចនាសម្ព័ន្ធឡើងវិញ

៧០ ខាងក្រោមនេះ គឺជាឧទាហរណ៍ពីព្រឹត្តិការណ៍ដែលអាចស្ថិតនៅក្នុងនិយមន័យ នៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ ÷

(ក) ការលក់ ឬ ការបញ្ឈប់ខ្សែអាជីវកម្មមួយ

(ខ) ការបិទទីតាំងអាជីវកម្ម នៅក្នុងប្រទេសមួយ ឬតំបន់មួយ ឬការផ្ទេរទីតាំងអាជីវកម្មពីប្រទេសមួយទៅប្រទេសមួយទៀត ឬពីតំបន់មួយទៅតំបន់មួយទៀត ។

(គ) ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ឧទាហរណ៍ ដូចជាការបំបាត់ចោលនូវស្រទាប់អ្នក គ្រប់គ្រងមួយ ។ និង

(ឃ) ការរៀបចំសហគ្រាសឡើងវិញដ៏សំខាន់ៗ ដែលមានឥទ្ធិពលជាសារវ័ន្តចំពោះលក្ខណៈនិង ចំណុចស្នូលនៃកិច្ចប្រតិបត្តិការរបស់សហគ្រាស ។

៧១ សំវិធានធនសម្រាប់ចំណាយលើការរៀបចំរចនាសម្ព័ន្ធឡើងវិញ ត្រូវបានទទួលស្គាល់ តែនៅពេលលក្ខណៈវិនិច្ឆ័យ ជាទូទៅសម្រាប់ទទួលស្គាល់សំវិធានធន ដែលបានចែងក្នុងកថាខណ្ឌទី១៤ ត្រូវបានបំពេញ។ កថាខណ្ឌ ទី៧២-៨៣ បានចែងអំពីរបៀបដែលលក្ខណៈវិនិច្ឆ័យជាទូទៅអនុវត្តចំពោះការរៀបចំរចនាសម្ព័ន្ធឡើងវិញ ។

**៧២ កាតព្វកិច្ចប្រយោល ដើម្បីរៀបចំរចនាសម្ព័ន្ធឡើងវិញ កើតឡើងតែនៅពេលដែលសហគ្រាសមួយ ÷**

(ក) មានផែនការលំអិតជាផ្លូវការមួយ សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដែលអាចកំណត់យ៉ាងហោចណាស់ :

(១) អាជីវកម្ម ឬផ្នែកមួយ នៃអាជីវកម្មដែលពាក់ព័ន្ធ

(២) ទីតាំងសំខាន់របស់សហគ្រាសបានរងផលប៉ះពាល់

(៣) ទីតាំង មុខងារ និង ចំនួននិយោជិកប្រហាក់ប្រហែលដែលនឹងត្រូវបានសងជំងឺចិត្ត ចំពោះការបញ្ឈប់ការងាររបស់ពួកគេ ។

(៤) ចំណាយទាំងអស់ដែលនឹងត្រូវប្រើ

(៥) ពេលវេលាដែលផែនការនឹងត្រូវបានអនុវត្ត និង

(ខ) បានបង្កើតឡើងនូវការរំពឹងទុកដ៏ត្រឹមត្រូវនៅក្នុងផែនការដែលបានប៉ះពាល់ដែលសហគ្រាសនឹង អនុវត្តការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដោយការចាប់ផ្តើមអនុវត្តផែនការនោះ ឬដោយការផ្សព្វផ្សាយនូវលក្ខណៈពិសេសទៅដល់អ្នកដែលរងឥទ្ធិពលទាំងនោះ ។

៧៣ ភស្តុតាងដែលធ្វើឱ្យសហគ្រាសមួយចាប់ផ្តើមអនុវត្តផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដែលត្រូវបានផ្តល់ (ឧទាហរណ៍) ដោយការរុះរើរោងចក្រ ឬលក់អចលនទ្រព្យ ឬដោយការប្រកាសជាសាធារណៈ ពីលក្ខណៈពិសេសរបស់ផែនការ។ ការប្រកាសជាសាធារណៈពីផែនការលំអិតមួយសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញបានបង្កើតនូវកាតព្វកិច្ចប្រយោល ដើម្បីរៀបចំរចនាសម្ព័ន្ធឡើងវិញ តែប៉ុណ្ណោះប្រសិនបើវា ត្រូវបានបង្កើតឡើងដោយបែបនោះ និងនៅក្នុងភាពល្អិតល្អន់គ្រប់គ្រាន់ (ពោលគឺ កំណត់ពីលក្ខណៈពិសេសរបស់ផែនការ) ដែលផ្តល់ឱ្យនូវការរំពឹងទុកដ៏ត្រឹមត្រូវនៅក្នុងភាគីដទៃទៀត ដូចជា អតិថិជន អ្នកផ្គត់ផ្គង់ និង និយោជិក (ឬក៏តំណាងរបស់ពួកគេ) សហគ្រាសនឹងអនុវត្តនូវការរៀបចំរចនាសម្ព័ន្ធឡើងវិញ ។

៧៤- សម្រាប់ផែនការមួយ នឹងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីនាំឲ្យកើនឡើងចំពោះកាតព្វកិច្ចប្រយោល គឺនៅពេលដែល វាត្រូវបានផ្សាយ ចំពោះកាតព្វកិច្ចដែលបានរងឥទ្ធិពលដោយសារផែនការ ការអនុវត្តរបស់វាទាមទារឱ្យមានផែនការ ដើម្បីចាប់ផ្តើមឱ្យបានឆាប់រហ័ស និងត្រូវបានបញ្ចប់ទៅតាមគំរោងពេលវេលាមួយ ដែលធ្វើឱ្យការផ្លាស់ប្តូរគំរោងមិនទំនងជាកើតឡើង។ ប្រសិនបើវា ត្រូវបានរំពឹងថានឹងមានការពន្យារពេលដ៏វែងមួយ មុនពេលការចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធឡើងវិញ ឬថាការរៀបចំរចនាសម្ព័ន្ធឡើងវិញនោះ នឹងប្រើប្រាស់ពេលវេលាយូរ ដោយមិនសមហេតុផល នោះវាពុំទំនងថា ផែនការនឹងនាំឱ្យមានការរំពឹងទុកដ៏ត្រឹមត្រូវទៅលើផ្នែករបស់ភាគីផ្សេងទៀត ដែលសហគ្រាសនាពេលបច្ចុប្បន្ន

បានសន្យាចំពោះការរៀបចំរចនាសម្ព័ន្ធឡើងវិញ ពីព្រោះពេលវេលាបានផ្តល់ឱកាសឱ្យសហគ្រាសដើម្បីធ្វើការផ្លាស់ប្តូរផែនការរបស់វា ។

៧៥ ការសំរេចចិត្តរបស់អ្នកគ្រប់គ្រង ឬក្រុមប្រឹក្សាភិបាលដែលបានធ្វើឡើងនៅមុនចុងការិយបរិច្ឆេទដើម្បីរៀបចំរចនាសម្ព័ន្ធឡើងវិញវាពុំបណ្តាលឱ្យមានកាតព្វកិច្ចប្រយោលនៅចុងការិយបរិច្ឆេទរាយការណ៍ទេ លុះត្រាតែមុនចុងការិយបរិច្ឆេទរាយការណ៍ សហគ្រាស ÷

(ក) បានចាប់ផ្តើមអនុវត្តនូវផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញ

(ខ) បានប្រកាស នូវលក្ខណៈពិសេសៗ របស់ផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញ ទៅកាន់អ្នក ដែលទទួលរងឥទ្ធិពលពីវានៅក្នុងលក្ខណៈជាក់ស្តែងយ៉ាងគ្រប់គ្រាន់ ដើម្បីបង្កើនការរំពឹងទុលដែលមានសុពលភាពនៅក្នុងលក្ខណៈពិសេសដែលសហគ្រាសនឹងអនុវត្តការរៀបចំរចនាសម្ព័ន្ធឡើងវិញ។

ប្រសិនបើ សហគ្រាសមួយចាប់ផ្តើមផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញ ឬប្រកាសពីលក្ខណៈពិសេសសំខាន់ៗ របស់ផែនការទៅកាន់អ្នក ដែលទទួលរងនូវឥទ្ធិពលពីវា តែនៅពេលបន្ទាប់ពី ការិយបរិច្ឆេទរាយការណ៍ នោះការការលាតត្រដាងព័ត៌មានត្រូវបានតម្រូវតាមស្តង់ដា ស.គ.អ.ក ១០ *ព្រឹត្តការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍* ប្រសិនបើ ការរៀបចំរចនាសម្ព័ន្ធឡើងវិញនោះ មានភាពជាសារវន្ត ហើយការមិនបានលាតត្រដាងព័ត៌មាន អាចប៉ះពាល់ដល់ការសំរេចចិត្តផ្នែកសេដ្ឋកិច្ច ដែលអ្នកប្រើប្រាស់ធ្វើការសំរេចចិត្តដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុ។

៧៦ ទោះបីជាកាតព្វកិច្ចប្រយោលមួយ មិនត្រូវបានបង្កើតតែឯង ដោយការសេចក្តីសំរេចចិត្តរបស់អ្នកគ្រប់គ្រង ក៏ដោយក៏កាតព្វកិច្ចនោះអាចកើតចេញពីព្រឹត្តិការណ៍មុនៗដទៃទៀតរួមជាមួយសេចក្តីសំរេចចិត្តនេះផងដែរ។

ជាឧទាហរណ៍

ការចរចារជាមួយនឹងតំណាងបុគ្គលិកសម្រាប់ការទូទាត់សងវិញចំពោះការបញ្ឈប់ការងារ ឬការចរចារជាមួយអ្នកទិញអំពីការលក់កិច្ចប្រតិបត្តិការ អាចត្រូវបានសន្មត់ថា បញ្ចប់ជាកម្មវត្ថុនៃការ អនុម័តតែប៉ុណ្ណោះ។ នៅពេលដែលការអនុញ្ញាតត្រូវបានទទួល ហើយត្រូវបានផ្សាយ ជូនដំណឹងទៅភាគីផ្សេង ទៀតរួចហើយ នោះសហគ្រាសមានកាតព្វកិច្ច ប្រយោលដើម្បីរៀបចំរចនាសម្ព័ន្ធឡើងវិញ ប្រសិនបើ លក្ខខណ្ឌនៅក្នុង កថាខណ្ឌលេខ៧២ ត្រូវបានបំពេញ ។

៧៧- នៅក្នុងប្រទេសខ្លះ សិទ្ធិអំណាចចុងក្រោយបង្អស់ ត្រូវបានផ្ទេរនៅក្នុងក្រុមប្រឹក្សាភិបាល ដែលអ្នកតំណាង រួមបញ្ចូលនូវអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ ក្រៅពីផលប្រយោជន៍របស់គណៈគ្រប់គ្រងក្រុមអ្នកគ្រប់គ្រង ( ឧ. និយោជិក) ឬការជូនដំណឹងទៅឲ្យអ្នកតំណាងបែបនេះ អាចមានចាំបាច់មុនការសំរេចរបស់ក្រុមប្រឹក្សាភិបាលដែលបានធ្វើឡើង។ ដោយសារតែការសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលនេះ ជាប់ទាក់ទិននឹងការជូនដំណឹងដល់អ្នកតំណាងទាំងនេះ វានឹងនាំឲ្យកើតមានកាតព្វកិច្ចប្រយោលក្នុងការរៀបចំរចនាសម្ព័ន្ធឡើងវិញ។

៧៨ **ពុំមានកាតព្វកិច្ចកើតឡើង សម្រាប់ការលក់កិច្ចប្រតិបត្តិការរហូតដល់សហគ្រាសមានការប្តេជ្ញាចំពោះ ការលក់នោះ ពោលគឺមានកិច្ចព្រមព្រៀងលក់។**

៧៩ ទោះបីជាសហគ្រាសមួយបានសំរេចចិត្តដើម្បីលក់កិច្ចប្រតិបត្តិការ ហើយបានប្រកាសពីការសំរេចនោះជាសាធារណៈក៏ដោយ ក៏វាមិនអាចត្រូវបានសន្យាចំពោះការលក់រហូតដល់អ្នកទិញត្រូវបានធ្វើអត្តសញ្ញាណ និងមានកិច្ចព្រមព្រៀងលក់។ រហូតដល់មានកិច្ចព្រមព្រៀងលក់ សហគ្រាសនឹងអាចមានលទ្ធភាព ដើម្បីប្តូរចិត្ត ហើយភាពជាក់ស្តែងនឹងត្រូវមានសកម្មមួយផ្សេងទៀត ប្រសិនបើអ្នកទិញមិនអាចត្រូវបានរកឃើញ លើលក្ខខណ្ឌដែលអាចទទួលយកបាន។ នៅពេលដែលការលក់កិច្ចប្រតិបត្តិការត្រូវបានគ្របដណ្តប់ជាផ្នែកមួយនៃការរៀបរចនាសម្ព័ន្ធឡើងវិញ ទ្រព្យសកម្មនៃកិច្ចប្រតិបត្តិការ ត្រូវបានពិនិត្យឡើងវិញ សម្រាប់ការធ្លាក់ចុះតំលៃ តាម ស.រ.ហ.អ.ក ៣៦។ នៅពេលដែលការលក់ គឺជាផ្នែកតែមួយនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ នោះកាតព្វកិច្ចប្រយោលអាចកើតឡើងសម្រាប់ផ្នែកផ្សេងទៀតនៃការរៀបចំរចនាសម្ព័ន្ធមុនកិច្ចព្រមព្រៀងលក់កើតឡើង ។

៨០ **សំវិធានធន សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ត្រូវរួមបញ្ចូលតែចំណាយផ្ទាល់ ដែលកើតពីការរៀបចំ រចនាសម្ព័ន្ធឡើងវិញ ដែលជាចំណាយដែល ÷**

**(ក) ត្រូវការចាំបាច់ដោយសារការរៀបចំរចនាសម្ព័ន្ធឡើងវិញ និង**

**(ខ) មិនទាក់ទងនឹងដំណើរប្រព្រឹត្តទៅរបស់សហគ្រាស**

៨១ សំវិធានធន សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ពុំរាប់បញ្ចូលនូវចំណាយ ដូចជា ÷

(ក) កាហ្វឹកហ្វឺនឡើងវិញ ឬការផ្លាស់ប្តូរទីកន្លែងការងាររបស់បុគ្គលដែលនៅធ្វើការបន្ត

(ខ) ការស្វែងរកទីផ្សារ

(គ) ការវិនិយោគទុនលើប្រព័ន្ធថ្មី និង បណ្តាញចែកចាយថ្មី ។

ចំណាយទាំងនេះទាក់ទងនឹងការប្រតិបត្តិការ នៃអាជីវកម្មនាពេលអនាគត ហើយវាពុំមែនជាបំណុល សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញនៅចុងការិយបរិច្ឆេទរាយការណ៍ទេ។ ការចំណាយបែបនេះ ត្រូវបានទទួលស្គាល់លើមូលដ្ឋានដូចគ្នា ប្រសិនបើវាកើតឡើង ដោយមិនអាស្រ័យទៅនឹងការរៀបចំរចនាសម្ព័ន្ធឡើងវិញ នោះទេ ។

៨២ ការខាតបង់ពីកិច្ចប្រតិបត្តិការ ដែលអាចកំណត់ នៅពេលអនាគត រហូតត្រឹមកាលបរិច្ឆេទ នៃការរៀបចំរចនា សម្ព័ន្ធឡើងវិញ គឺមិនត្រូវបានរួមបញ្ចូលនៅក្នុងសំវិធានធនទេ លុះត្រាតែវាទាក់ទងនឹងកិច្ចសន្យា ដែលនាំឱ្យមានការខាតបង់ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១០ ។

៨៣ ដូចដែលបានតម្រូវនៅក្នុង កថាខណ្ឌទី ៥១ ចំណេញពីការលក់ចោលទ្រព្យសកម្មដែលបានរំពឹងទុកមិនត្រូវបានគេយកមកពិចារណា នៅក្នុងការវាស់វែងសំវិធានធន សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញទេ ទោះបីជាការលក់ចោលទ្រព្យសកម្ម ត្រូវបានគ្របដណ្តប់ជាផ្នែកមួយនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញក៏ដោយ។

៨៤ សម្រាប់ថ្នាក់នីមួយៗរបស់សំវិធានធន សហគ្រាសមួយត្រូវតែធ្វើកំណត់បង្ហាញ ៖

(ក) តម្លៃយោងនៅដើម និង ចុងការិយបរិច្ឆេទ

(ខ) សំវិធានធនបន្ថែមដែលបានធ្វើឡើងនៅក្នុងការិយបរិច្ឆេទ ដោយរួមបញ្ចូលទាំងការកើនឡើងនៃសំវិធានធនដែលមានស្រាប់

(គ) ទឹកដែលបានប្រើ (ពោលគឺ បានកើតឡើង និងបានដាក់បន្ទុកជាមួយសំវិធានធន) ក្នុងកំឡុងការិយបរិច្ឆេទ។

(ឃ) ទឹកប្រាក់មិនបានប្រើ ដែលបានកត់ត្រាបញ្ច្រាស់ក្នុងកំឡុងការិយបរិច្ឆេទ និង

(ង) ការកើនឡើងក្នុងកំឡុងការិយបរិច្ឆេទតាមទឹកប្រាក់អប្បហាររួចដែលកើតចេញពីការកន្លងផុតនៃពេលវេលា និងឥទ្ធិពលនៃការប្រែប្រួលនៅក្នុងអត្រាអប្បហារ។ ព័ត៌មានប្រៀបធៀបមិនត្រូវបានតម្រូវទេ។

៨៥ សហគ្រាសមួយ ត្រូវតែធ្វើលាតត្រដាង ដូចខាងក្រោមនេះ សម្រាប់រាល់ថ្នាក់នីមួយៗ នៃសំវិធានធនៈ

(ក) ការពិពណ៌នា ដោយសង្ខេបពីលក្ខណៈរបស់កាតព្វកិច្ច និងពេលវេលាបានរំពឹងទុក នៃលំហូរចេញ នៃផលប្រយោជន៍សេដ្ឋកិច្ច។

(ខ) ការចង្អុលបង្ហាញ ពីភាពមិនប្រាកដប្រជា ទៅលើចំនួនទឹកប្រាក់ ឬ ពេលវេលា នៃលំហូរចេញ ទាំងនោះ។ នៅពេលដែលចាំបាច់ត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ សហគ្រាសមួយត្រូវតែ

ធ្វើការលាតត្រដាងព័ត៌មានពីការសន្មតសំខាន់ៗដែលធ្វើឡើង ដែលទាក់ទងនឹងព្រឹត្តការណ៍នាពេលអនាគត ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៤៨ និង

(គ) ចំនួនទឹកប្រាក់នៃការទូទាត់សងវិញណាមួយ ដែលបានរំពឹងទុក ដោយបង្ហាញពីទឹកប្រាក់នៃទ្រព្យសកម្មទាំងឡាយណា ដែលត្រូវបានទទួលស្គាល់សម្រាប់ធ្វើការទូទាត់សងវិញដែលបានរំពឹងទុកនោះ។

៨៦ លុះត្រាតែ លទ្ធភាពនៃលំហូរចេញណាមួយនៅក្នុងការទូទាត់សង មានលក្ខណៈដាច់ស្រយាល សហគ្រាសមួយ ត្រូវលាតត្រដាងសម្រាប់ថ្នាក់នីមួយៗ នៃបំណុលយថាហេតុ នៅចុងការិយបរិច្ឆេទរាយការណ៍ នូវការពិព័ណនាដោយសង្ខេបនូវលក្ខណៈរបស់បំណុលយថាហេតុ និងនៅពេលដែលអាចអនុវត្តបានៈ

(ក) ការប៉ាន់ស្មានពីឥទ្ធិពលហិរញ្ញវត្ថុរបស់វា ដែលបានវាស់វែងទៅតាមកថាខណ្ឌទី៣៦-៥២

(ខ) ការចង្អុលបង្ហាញនូវភាពមិនប្រាកដប្រជាដែលទាក់ទង នឹងចំនួនទឹកប្រាក់ ឬ ពេលវេលា នៃការលំហូរចេញណាមួយ និង

(គ) ភវនីយភាពនៃការទូទាត់សងវិញណាមួយ

៨៧ នៅក្នុងការកំណត់ថា តើសំវិធានធនឬបំណុលយថាហេតុណាត្រូវបានសរុបបញ្ចូលគ្នា ដើម្បីបង្កើតជាថ្នាក់មួយវាចាំបាច់ ត្រូវពិចារណា ថាតើលក្ខណៈរបស់ធាតុទាំងនេះ គឺប្រហាក់ប្រហែលគ្នាយ៉ាងគ្រប់គ្រាន់សម្រាប់

ការធ្វើរបាយការណ៍តែមួយ ដើម្បីបំពេញទៅតាមតម្រូវការដែលមានចែង នៅក្នុងកថាខណ្ឌ៨៥(ក) និង (ខ) និង ៨៦(ក) និង (ខ)។ ដូច្នេះ វាសមស្របដែលត្រូវចាត់ទុកជាថ្នាក់តែមួយនៃសំវិធានធន ដែលទាក់ទងនឹងការធានាលើផលិតផលផ្សេងគ្នា ប៉ុន្តែវានឹងមិនសមស្របឡើយ ចំពោះការចាត់ទុកចំនួនទឹកប្រាក់ថ្នាក់តែមួយ ដែលទាក់ទងនឹងការធានាលើផលិតផលធម្មតា ហើយចំនួនទឹកប្រាក់ដែលស្ថិតនៅក្នុងបណ្តឹងតាមផ្លូវច្បាប់

៨៨ នៅពេលដែលសំវិធានធន និងបំណុលយថាហេតុ កើតឡើងមកពីសំណុំកាលៈទេសៈដូចគ្នា សហគ្រាសធ្វើការលាតត្រដាងដែលបានតម្រូវ ដោយកថាខណ្ឌ ៨៤-៨៦ នៅក្នុងរបៀបមួយដែលបង្ហាញពី ទំនាក់ទំនងរវាងសំវិធានធន និងបំណុលយថាហេតុ។

**៨៩ នៅពេលដែលការលំហូរចូលនៃផលប្រយោជន៍សេដ្ឋកិច្ច គឺទំនងជាកើតឡើង សហគ្រាសត្រូវតែលាតត្រដាងបង្ហាញនូវការបរិយាយសង្ខេបពីលក្ខណៈរបស់ទ្រព្យសកម្មយថាហេតុនោះ នៅចុងការិយបរិច្ឆេទនិង ប្រសិនបើ អាចអនុវត្តបាន ការប៉ាន់ស្មាននៃឥទ្ធិពលហិរញ្ញវត្ថុ ដែលបានវាស់វែង ដោយប្រើប្រាស់គោលការណ៍ដែលបានចែងសម្រាប់សំវិធានធននៅក្នុងកថាខណ្ឌ ៣៦-៥២ ។**

៩០ វាមានសារៈសំខាន់ដែលការលាតត្រដាងពីទ្រព្យសកម្មយថាហេតុ អាចជៀសវាងបានផ្តល់នូវការចង្អុលបង្ហាញភ័ន្តច្រឡំពីភាព ដែលអាចកើតមានឡើងនៃចំណូល ។

៩១ នៅពេលដែលព័ត៌មានណាមួយ ដូចដែលបានតម្រូវដោយកថាខណ្ឌ ៨៦ និង ៨៩ មិនត្រូវបានលាតត្រដាង បង្ហាញដោយសារតែ វាមិនអាចធ្វើទៅបាននោះ ត្រូវតែធ្វើការបញ្ជាក់ពីការពិតនៃហេតុការណ៍នោះ។

៩២ ក្នុងករណីកម្របំផុត ការលាតត្រដាងព័ត៌មានខ្លះៗ ឬ ព័ត៌មានទាំងអស់ដែលបានតម្រូវដោយកថាខណ្ឌ ៨៤-៨៩ អាចត្រូវបានរំពឹងទុកថាបណ្តាលឱ្យលំអៀងយ៉ាងធ្ងន់ធ្ងរ ពីស្ថានភាពរបស់សហគ្រាសនៅក្នុងជំលោះ ជាមួយ ភាគីដទៃទៀត ចំពោះបញ្ហាកម្មវត្ថុរបស់សំវិធានធនបំណុលយថាហេតុ ឬទ្រព្យសកម្មយថាហេតុ។ ក្នុងករណីបែបនេះសហគ្រាសមួយមិនចាំបាច់លាតត្រដាងបង្ហាញពីព័ត៌មាននោះទេ ប៉ុន្តែត្រូវតែធ្វើការលាតត្រដាងបង្ហាញ ពីលក្ខណៈទូទៅនៃទំនាស់ រួមជាមួយនឹងការពិត និង មូលហេតុដែលព័ត៌មាននោះនៅមិនទាន់បានបង្ហាញ ។

## អន្តរបញ្ញត្តិ

៩៣ ប្រសិទ្ធភាពនៃការអនុវត្តទៅតាមស្តង់ដានេះ នៅកាលបរិច្ឆេទចូលជាធរមាន (ឬមុន) គួរ តែត្រូវបានរាយការណ៍ជានិយ័តភាព លើសមតុល្យគណនីប្រាក់ចំណេញរក្សាទុកនាដើមគ្រា សម្រាប់គ្រាដែលស្តង់ដានេះ ត្រូវបានប្រើជាដំបូង។ សហគ្រាសត្រូវបានជំរុញការលើកទឹកចិត្តឱ្យអនុវត្តតាម ប៉ុន្តែមិនបានតម្រូវឱ្យធ្វើនិយ័តភាពសមតុល្យដើមគ្រា លើគណនីប្រាក់ចំណេញរក្សា ទុកសម្រាប់ការិយបរិច្ឆេទដំបូងបង្អស់ដែលបានដាក់បង្ហាញ និងដើម្បីបញ្ជាក់ ពីព័ត៌មានប្រៀបធៀបឡើងវិញឡើយ។ ប្រសិនបើព័ត៌មានប្រៀបធៀបមិនត្រូវបានបង្ហាញឡើងវិញទេ ហេតុការណ៍នោះនឹងត្រូវលាតត្រដាង។

៩៤ [លុបចោល]

**កាលបរិច្ឆេទចូលជាធរមាន**

---

៩៥ ស្តង់ដានេះ ចូលជាធរមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩។ សហគ្រាសណាដែលមានការអនុវត្តមុនកាលកំណត់នឹងបានលើកទឹកចិត្ត។

៩៦ [លុបចោល]

៩៧ ស.រ.ហ.អ.ក ៩ ដែលបានចេញផ្សាយនៅក្នុង ខែតុលា ឆ្នាំ២០១០ បានធ្វើវិសោធនកម្មកថាខណ្ឌ ២។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្មនោះនៅពេលដែលអង្គភាពប្រើ ស.រ.ហ.អ.ក ៩ ដូចបានចេញផ្សាយ នៅក្នុងខែតុលា ឆ្នាំ ២០១០។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh



ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ